# វាក្យសព្ទច្បាប់ទី១
# នីតិបុគ្គល

**ក.** នីតិបុគ្គល ជាភាសាបរទេសភាសាអង់គ្លេស (legal person) ជាភាសាបារាំង (personne morale)។

**ខ.** ច្បាប់ខ្លះចែងផ្តល់ន័យថា "បុគ្គល"សំដៅដល់នីតិបុគ្គលនិងរូបវន្តបុគ្គល (ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាសអាវុធមហាប្រល័យ ច្បាប់ស្តីពីវិនិយោគ ច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក។

**គ.** ខ្លឹមសារដកស្រង់៖

**១.** នីតិបុគ្គលនៃនីតិសាធារណៈ គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចជាបុគ្គលដើម្បីជាផលប្រយោជន៍សាធារណៈ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខណ្ឌ បានផ្តល់នីតិបុគ្គលដល់រាជធានី ខេត្តក្រុង ស្រុកខណ្ឌ។

**២.** ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរ តែដទៃពីសមាជិកនៃខ្លួន ឧទាៈ ពុទ្ធិកសមាគម ជានីតិបុគ្គល ក្រុមហ៊ុនក៏ជានីតិបុគ្គលដែរ។ នីតិបុគ្គលនៃនីតិសាធារណៈសំដៅដល់ ក្រុមរាជការសាធារណៈ ឧទា ៖ រដ្ឋ ខេត្ត ឃុំ ឬគ្រឹះស្ថានសាធារណៈ ដូចជាសាកលវិទ្យាល័យជាដើម។ នីតិបុគ្គលនៃនីតិឯកជន មានសមាគម ក្រុមហ៊ុន ក្រុមមូលនិធិ (ច្បាប់ស្តីពីភូមិបាល)។

**៣.** នីតិបុគ្គលសញ្ជាតិខ្មែរ មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងភាគហ៊ុន៥១% ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ (ច្បាប់ស្តីពីវិនិយោគ) ។

**៤.** ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាស ឬអង្គការនានា ដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកចំណេញ។ ចំពោះបុគ្គលអនិវាសជន ពាក្យ "នីតិបុគ្គល" សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេនូវក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល (ច្បាប់ស្តីពីសារពើពន្ធ)។

នីតិបុគ្គលមានដូចជាក្រុមហ៊ុនទីប្រឹក្សា (ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ), ក្រុមហ៊ុនអាណត្តិព្យាបាល (ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម)។ នីតិបុគ្គលមានច្រើនប្រភេទ

ដូចមានចែងខាងលើក្នុងនោះក៏មាននីតិបុគ្គលប្រតិស្រុតផងដែរ (Permitted Entity) (ច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន)។

នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។ មាត្រា៤២នៃក្រមព្រហ្មទណ្ឌចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ក្នុងខ្លឹមសារថា៖

*នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់និងបទដ្ឋានគតិយុត្តិផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។*

*ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដែលនោះទេ។*

សូមមើលបន្ថែមអត្ថបទស្តីពី ការទទួលខុសត្រូវរបស់នីតិបុគ្គល។